# សេចក្តីណែនាំ

## ស្តីពី

## ការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យរ៉ែនិងប្រេងកាត
## របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៥០.១៤.ពាមន

# សេចក្ដីណែនាំ
# ស្ដីពី
# ការអនុវត្តមុខងារផ្ដល់សេវារដ្ឋបាលក្នុងវិស័យរ៉ែនិងប្រេងកាត
# របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

អនុលោមតាមអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង អនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក និងអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានមុខងារផ្ដល់សេវាសាធារណៈលើវិស័យរ៉ែ និងប្រេងកាត រួមមាន៖

១- ការផ្ដល់និងការចុះបញ្ជីអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្ដៅដីចល័តដែលមានក្រឡាផ្ទៃមិនលើសពី០,៥ហិកតា និងជម្រៅមិនលើសពី៣ម៉ែត្រ ឬប្រតិបត្តិការបកយកអាចម៍ដីដែលមានក្រឡាផ្ទៃមិនលើសពី១ហិកតា និងជម្រៅមិនលើសពី១ម៉ែត្រ។

២- ការចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់។

៣-ការគ្រប់គ្រងនិងការផ្ដល់លិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់ឧស្ម័នឥន្ធនៈក្នុងកំប៉ុងនិង/ឬធុងដែលមានចំណុះ៤៥គីឡូក្រាមចុះក្រោម។

៤-ការគ្រប់គ្រងនិងការផ្ដល់លិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់និងប្ដូរប្រេងរំអិល។

ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តមុខងារខាងលើនេះ ក្រសួងរ៉ែនិងថាមពលសូមធ្វើការណែនាំដូចខាងក្រោម៖

## I-ការងារវិស័យរ៉ែ

### ១. ការផ្ដល់និងការចុះបញ្ជីអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដីរណ្ដៅដីចល័តដែលមានក្រឡាផ្ទៃមិនលើសពី០,៥ហិកតា និងជម្រៅមិនលើសពី៣ម៉ែត្រ ឬប្រតិបត្តិការបកយកអាចម៍ដីដែលមានក្រឡាផ្ទៃមិនលើសពី១ហិកតា និងជម្រៅមិនលើសពី១ម៉ែត្រ

#### ក. គោលការណ៍នៃការផ្ដល់សេវា

អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្ដៅដីចល័ត អាចផ្ដល់ជូនចំពោះពលរដ្ឋខ្មែរដែលមានបំណងធ្វើអាជីវកម្មអាចម៍ដីនៅលើដីកម្មសិទ្ធិឯកជន។ អាជ្ញាបណ្ណនេះមានសុពលភាព

សម្រាប់ការធ្វើអាជីវកម្មជីកអាចម៍ដី រណ្តៅដីចល័តនៅក្នុងក្រុង ស្រុក ខណ្ឌដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានផ្តល់អាជ្ញាបណ្ណ។ ប្រតិបត្តិការជាក់ស្តែងនៅលើទីតាំងជាក់លាក់ណាមួយនៅតាមបណ្តាភូមិ ឃុំ សង្កាត់នីមួយៗក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវមានលិខិតអង្កេតសុវិធាន អសុវិធាន ចេញដោយរដ្ឋបាលឃុំ សង្កាត់។

## ខ. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

ប្រជាពលរដ្ឋគ្រប់រូបដែលមានបំណងធ្វើសេវាកម្មជីករាចម៍ដី រណ្តៅដីចល័ត ត្រូវមកទទួលពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រូវបំពេញពាក្យស្នើសុំដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃវិស័យរ៉ែដូចខាងក្រោម៖

១-ពាក្យស្នើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត........................................ចំនួន១ច្បាប់

២- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរថតចម្លងដោយមានការបញ្ជាក់ពីអាជ្ញាធរឬស្ថាប័នមានសមត្ថកិច្ច........................................ចំនួន១ច្បាប់

៣- សៀវភៅស្នាក់នៅថតចម្លងដោយមានការបញ្ជាក់ពីអាជ្ញាធរឬស្ថាប័នមានសមត្ថកិច្ច........................................ចំនួន១ច្បាប់

៤- រូបថត ៤x៦........................................ចំនួន៣សន្លឹក

## គ. នីតិវិធីនៃការផ្តល់សេវា

បន្ទាប់ពីបំពេញពាក្យស្នើសុំនិងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវនិងគ្រប់គ្រាន់ ប្រជាពលរដ្ឋត្រូវយកដាក់ពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងស្នើសុំនោះស្ថិតនៅ។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំពីប្រធានការិយាល័យច្រកចេញចូលតែមួយ បុគ្គលិកទទួលបន្ទុកវិស័យរ៉ែត្រូវពិនិត្យនិងវាយតម្លៃលើពាក្យស្នើសុំ និងពិនិត្យវាយតម្លៃពីបុគ្គលិកលក្ខណៈសម្បត្តិរបស់អ្នកស្នើសុំឱ្យបានគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើប្រវត្តិអាជីវកម្មពីមុន បើមាន
- បុគ្គលិកទទួលបន្ទុកវិស័យរ៉ែត្រូវរៀបចំ "កំណត់បង្ហាញរឿង" ដោយមានភ្ជាប់មកជាមួយនូវការវាយតម្លៃពីបុគ្គលិកលក្ខណៈសម្បត្តិរបស់អ្នកស្នើសុំ ព្រមទាំងរៀបចំសេចក្តីព្រាងអាជ្ញាបណ្ណនិងសេចក្តីសម្រេចស្តីពីលក្ខខណ្ឌអាជ្ញាបណ្ណ (គំរូអាជ្ញាបណ្ណនិងគំរូសេចក្តីសម្រេចស្តីពីលក្ខខណ្ឌអាជ្ញាបណ្ណត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃវិស័យរ៉ែ) ឬលិខិតឆ្លើយតបក្នុងករណីបដិសេធដោយត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ រួចបញ្ជូនទៅប្រធានការិយាល័យច្រកចេញចូលតែមួយ
- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីបុគ្គលិកទទួលបន្ទុកវិស័យរ៉ែលើ "កំណត់បង្ហាញរឿង" ប្រធានការិយាល័យច្រកចេញចូលតែមួយត្រូវបញ្ជូនសំណុំឯកសារស្នើសុំ សេចក្តីព្រាងអាជ្ញា-បណ្ណនិងសេចក្តីសម្រេចស្តីពីលក្ខខណ្ឌអាជ្ញាបណ្ណ ឬលិខិតឆ្លើយតបក្នុងករណីបដិសេធជូនអភិបាលក្រុង ស្រុក ខណ្ឌ ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

ក្នុងការពិនិត្យសម្រេចផ្ដល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្ដៅដីចល័ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវ ៖

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ បទប្បញ្ញត្តិស្ដីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន និង
- មានសង្គតិភាពជាមួយនឹងផែនការអភិវឌ្ឍដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានអនុម័ត។

ក្រោយពីទទួលបានការជូនដំណឹងពីអ្នកទទួលបានអាជ្ញាបណ្ណអំពីទីតាំងជាក់ស្ដែងដែលត្រូវជីកយកអាចម៍ដី រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់មន្ត្រីក្នុងការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ចុះពិនិត្យទីតាំងជាក់ស្ដែងដែលត្រូវជីកនិងទីតាំងដែលត្រូវចាក់បំពេញ។ ក្នុងការអនុញ្ញាតឱ្យជីកយកអាចម៍ដីត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

- រក្សាគម្លាតសុវត្ថិភាពយ៉ាងតិច២៥ម៉ែត្រពីមាត់រណ្ដៅទៅច្រាំងនៃបឹង ទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ ស្រះ
- រក្សាគម្លាតយ៉ាងតិច១០ម៉ែត្រពីមាត់រណ្ដៅដីនីមួយៗ និងមិនត្រូវជីកជាន់លើរណ្ដៅដីចាស់ដែលមានស្រាប់
- រក្សាគម្លាតយ៉ាងតិច៥ម៉ែត្រពីមាត់រណ្ដៅទៅព្រំដីនៅជុំវិញ និង
- តម្រូវឱ្យអ្នកទទួលបានអាជ្ញាបណ្ណប្រគល់លិខិតអង្កេតសុរិយាន អសុរិយានរបស់រដ្ឋបាលឃុំ សង្កាត់ ដើម្បីរក្សាទុកជាឯកសារ (គំរូលិខិតអង្កេតសុរិយាន អសុរិយាន ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃវិស័យរ៉ែ)។

ក្រោយពីទទួលបានការជូនដំណឹងពីអ្នកទទួលបានអាជ្ញាបណ្ណពីការបញ្ចប់ប្រតិបត្តិការជីកយកអាចម៍ដី រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់មន្ត្រីក្នុងការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ចុះត្រួតពិនិត្យទីតាំងជីកយកអាចម៍ដីនោះ ដើម្បីផ្ទៀងផ្ទាត់ពីអនុលោមភាពនិងកត់ត្រានូវបរិមាណអាចម៍ដីដែលបានជីកយកសម្រាប់ជាមូលដ្ឋាននៃការប្រមូលសួយសារ។

## ឃ. ការកំណត់កម្រៃអាជ្ញាបណ្ណនិងកម្រៃសេវាចុះបញ្ជីអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្ដៅដីចល័ត

នៅពេលដែលប្រជាពលរដ្ឋមកទទួលអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្ដៅដីចល័ត អ្នកទទួលអាជ្ញាបណ្ណត្រូវបង់កម្រៃសេវាសម្រាប់ការចុះបញ្ជីអាជ្ញាបណ្ណដែលខ្លួនបានទទួលនោះ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ចែងចុះបញ្ជីអាជ្ញាបណ្ណជូនអ្នកទទួលអាជ្ញាបណ្ណនោះ (គំរូបញ្ជីអាជ្ញាបណ្ណត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃវិស័យរ៉ែ)។

## ង. ការគ្រប់គ្រង

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបញ្ជីការផ្ដល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្ដៅដីចល័ត ដែលមានទីតាំងនៅក្នុងមូលដ្ឋានរបស់ខ្លួននិងត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់យ៉ាងតិចមួយត្រីមាសម្ដង។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ចែងឱ្យមានការចុះត្រួតពិនិត្យជាប្រចាំយ៉ាងតិច១(មួយ) ខែម្តងនូវប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណដែលបានផ្តល់ជូន ដើម្បីធានាអនុលោមភាពតាមគោលការណ៍ដែលបានអនុញ្ញាតនិងបទដ្ឋានបច្ចេកទេសនានាពាក់ព័ន្ធនឹងនិរន្តរភាពបរិស្ថាន សង្គម សេដ្ឋកិច្ច និងបទដ្ឋានបច្ចេកទេសផ្សេងៗ។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចម្លងជូនមកមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់ នូវបញ្ជីអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត រៀងរាល់ដើមត្រីមាសនីមួយៗ។

បញ្ជីអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត ត្រូវបានតម្កល់នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យសាធារណជនងាយស្រួលមើល។

## ២. ការចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់

### ក. គោលការណ៍នៃការផ្តល់សេវា

ដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់សំដៅដល់ទីតាំងសន្និធិផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់សម្រាប់គោលបំណងពាណិជ្ជកម្ម។

ការចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់ អាចផ្តល់ជូនចំពោះបុគ្គលសញ្ជាតិខ្មែរដែលមានបំណងធ្វើអាជីវកម្មលក់ផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់នៅលើដីកម្មសិទ្ធិឯកជន។

### ខ. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

ប្រជាពលរដ្ឋគ្រប់រូបដែលមានបំណងចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់ត្រូវមកទទួលពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រូវបំពេញពាក្យស្នើសុំដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃវិស័យរ៉ែដូចខាងក្រោម៖

១- ពាក្យស្នើសុំចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស
និងថ្មសំណង់.................................................................... ចំនួន១ច្បាប់

២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងដោយមានការបញ្ជាក់ពីអាជ្ញាធរឬ
ស្ថាប័នមានសមត្ថកិច្ច.............................................................. ចំនួន១ច្បាប់

៣-សៀវភៅស្នាក់នៅថតចម្លងដោយមានការបញ្ជាក់ពីអាជ្ញាធរឬស្ថាប័នមាន
សមត្ថកិច្ច...................................................................... ចំនួន១ច្បាប់

៤- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុឬលិខិតសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ
នៃទីតាំងស្នើសុំឬកិច្ចសន្យាជួលថតចម្លងដោយមានបញ្ជាក់ពីអាជ្ញាធរ
ឬស្ថាប័នមានសមត្ថកិច្ច..........................................................ចំនួន១ច្បាប់

៥- លិខិតអង្កេតសុវិធាន អសុវិធាន (ចេញដោយរដ្ឋបាលឃុំ សង្កាត់)................ ចំនួន១ច្បាប់

៦- លក្ខន្តិកៈក្រុមហ៊ុននិងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មឬអាជ្ញាបណ្ណអណ្តូងរ៉ែ
បើកនិងការដ្ឋានវាយថ្មថតចម្លងដោយមានការបញ្ជាក់ពីអាជ្ញាធរឬស្ថាប័ន
មានសមត្ថកិច្ច (ក្នុងករណីជានីតិបុគ្គល) ..........................................ចំនួន១ច្បាប់

៧- រូបថត ៤x៦.................................................................. ចំនួន៣សន្លឹក

## គ. នីតិវិធីនៃការចុះបញ្ជី

បន្ទាប់ពីបំពេញពាក្យស្នើសុំនិងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវនិងគ្រប់គ្រាន់ ប្រជាពលរដ្ឋត្រូវយកដាក់ពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងស្នើសុំនោះស្ថិតនៅ។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំពីប្រធានការិយាល័យច្រកចេញចូលតែមួយ បុគ្គលិកទទួលបន្ទុកវិស័យរ៉ែត្រូវពិនិត្យនិងវាយតម្លៃលើពាក្យស្នើសុំនិងត្រូវចុះពិនិត្យវាយតម្លៃទីតាំងស្នើសុំលើទិដ្ឋភាពបរិស្ថាន សង្គម សេដ្ឋកិច្ច និងបទដ្ឋានបច្ចេកទេសឱ្យបានគ្រប់ជ្រុងជ្រោយ
- ក្នុងការចុះពិនិត្យវាយតម្លៃ បុគ្គលិកទទួលបន្ទុកវិស័យរ៉ែត្រូវរៀបចំរបាយការណ៍ពិនិត្យវាយតម្លៃទីតាំងចុះបញ្ជីដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់ (គំរូរបាយការណ៍ពិនិត្យវាយតម្លៃត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៦នៃវិស័យរ៉ែ) ដោយផ្តល់យោបល់ច្បាស់លាស់លើទិដ្ឋភាពបរិស្ថាន សង្គម សេដ្ឋកិច្ច និងបទដ្ឋានបច្ចេកទេសលើសេវាដែលបានស្នើសុំនោះ
- បុគ្គលិកទទួលបន្ទុកវិស័យរ៉ែត្រូវរៀបចំ "កំណត់បង្ហាញរឿង" ដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍ពិនិត្យវាយតម្លៃទីតាំងចុះបញ្ជីដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ ព្រមទាំងរៀបចំសេចក្តីព្រាងលិខិតបញ្ជាក់ការចុះបញ្ជី (គំរូលិខិតបញ្ជាក់ការចុះបញ្ជីត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៧នៃវិស័យរ៉ែ) ឬលិខិតឆ្លើយតបក្នុងករណីបដិសេធដោយត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ រួចបញ្ជូនទៅប្រធានការិយាល័យច្រកចេញចូលតែមួយ
- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីបុគ្គលិកទទួលបន្ទុកវិស័យរ៉ែលើ "កំណត់បង្ហាញរឿង" ប្រធានការិយាល័យច្រកចេញចូលតែមួយត្រូវបញ្ជូនសំណុំឯកសារស្នើសុំ និងសេចក្តីព្រាងលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតឆ្លើយតបក្នុងករណីបដិសេធជូនអភិបាលក្រុង ស្រុក ខណ្ឌ ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

ក្នុងការពិនិត្យសម្រេចផ្តល់លិខិតបញ្ជាក់ការចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

ក- អនុវត្តតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ខ- ផ្អែកលើលទ្ធផលវាយតម្លៃបច្ចេកទេស។

គ- មិនមានផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច សង្គម វប្បធម៌ ប្រពៃណី សុខភាព សុវត្ថិភាពសាធារណៈ សហគមន៍មូលដ្ឋាន និងបរិស្ថានធម្មជាតិ។

ឃ- មានសង្គតិភាពជាមួយនឹងផែនការអភិវឌ្ឍដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានអនុម័ត។

## ឃ. ការគ្រប់គ្រង

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបញ្ជីការផ្តល់លិខិតបញ្ជាក់ការចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់ ដែលមានទីតាំងនៅក្នុងមូលដ្ឋានរបស់ខ្លួននិងត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់យ៉ាងតិចមួយត្រីមាសម្តង។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ចែងឱ្យមានការចុះត្រួតពិនិត្យជាប្រចាំយ៉ាងតិច៦(ប្រាំមួយ) ខែម្តងនូវទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលប្រេងឥន្ធនៈ ក្រូស និងថ្មសំណង់ដែលបានផ្តល់ជូន ដើម្បីធានាអនុលោមភាពតាមគោលការណ៍ដែលបានអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនានាពាក់ព័ន្ធនឹងវិជ្ជភាពបរិស្ថាន សង្គម សេដ្ឋកិច្ច និងបទដ្ឋានបច្ចេកទេសផ្សេងៗ។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចម្លងជូនមកមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់ នូវការចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលប្រេងឥន្ធនៈ ក្រូស និងថ្មសំណង់ រៀងរាល់ដើមត្រីមាសនីមួយៗ។

## II.ការងារវិស័យប្រេងកាត

### ១.ការគ្រប់គ្រងនិងការអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់ឧស្ម័នឥន្ធនៈក្នុងកំប៉ុង និង/ឬក្នុងធុងដែលមានចំណុះ៤៥គីឡូក្រាមចុះក្រោម

#### ក. គោលការណ៍នៃការផ្តល់សេវា

លិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់ឧស្ម័នឥន្ធនៈ(អិលភីជី)ក្នុងកំប៉ុងនិង/ឬធុងដែលមានចំណុះ៤៥គីឡូក្រាមចុះក្រោម អាចផ្តល់បានដោយប្រើមធ្យោបាយស្តុកនិងកប្រិតសន្និធិជាក់ស្តែងសរុបដូចខាងក្រោម៖

-ប្រើកំប៉ុងនិង/ឬធុងដែលមានចំណុះ៤៥ (សែសិបប្រាំ)គីឡូក្រាមចុះក្រោម និង

-មានសន្និធិ(ស្តុក)ជាក់ស្តែងសរុបចាប់ពី១០១ (មួយរយមួយ)គីឡូក្រាម ដល់ ៥០ ០០០ (ហាសិបពាន់) គីឡូក្រាម។

ការអនុញ្ញាតឱ្យធ្វើអាជីវកម្មដូចចំណុចខាងលើមិនត្រូវអនុញ្ញាតឱ្យធ្វើសកម្មភាពច្រកបញ្ចូលឧស្ម័នឥន្ធនៈក្នុងកំប៉ុងឬធុងទេ។

#### ខ. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

បុគ្គលគ្រប់រូបដែលមានបំណងស្នើសុំលិខិតអនុញ្ញាតសន្និធិសម្រាប់អាជីវកម្មលក់ឧស្ម័នឥន្ធនៈក្នុងកំប៉ុងនិង/ឬធុង ឬមានបំណងស្នើសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតសន្និធិ ត្រូវមកទទួលពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រូវបំពេញពាក្យស្នើសុំដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃវិស័យប្រេងកាតដូចខាងក្រោម៖

១-ពាក្យស្នើសុំលិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់ឧស្ម័នឥន្ធនៈក្នុងកំប៉ុង និង/ឬធុងដែលមានចំណុះ៤៥គីឡូក្រាមចុះក្រោម.................................. ចំនួន១ច្បាប់

២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងដោយមានការបញ្ជាក់ពីអាជ្ញាធរឬស្ថាប័នមានសមត្ថកិច្ច................................................................ ចំនួន១ច្បាប់

៣- លក្ខន្តិកៈក្រុមហ៊ុននិងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានការបញ្ជាក់ពីអាជ្ញាធរឬស្ថាប័នមានសមត្ថកិច្ច(ក្នុងករណីជានីតិបុគ្គល)................ ចំនួន១ច្បាប់

៤- លិខិតប្រគល់សិទ្ធិជាតំណាង(ក្នុងករណីអ្នកស្នើសុំជាតំណាងឱ្យនីតិបុគ្គល)..... ចំនួន១ច្បាប់

៥- រូបថតម្ចាស់អាជីវកម្ម ឬប្រធានក្រុមហ៊ុន ៤x៦...................................ចំនួន៣សន្លឹក

**គ. នីតិវិធីនៃការផ្តល់សេវា**

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវនិងគ្រប់គ្រាន់ ប្រជាពលរដ្ឋត្រូវមកដាក់ពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងស្នើសុំនោះស្ថិតនៅ។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំពីប្រធានការិយាល័យច្រកចេញចូលតែមួយ បុគ្គលិកទទួលបន្ទុកវិស័យប្រេងកាតត្រូវពិនិត្យនិងវាយតម្លៃលើពាក្យស្នើសុំនិងត្រូវចុះពិនិត្យវាយតម្លៃទីតាំងស្នើសុំលើទិដ្ឋភាពបរិស្ថាន សង្គម សេដ្ឋកិច្ច និងបទប្បញ្ញត្តិបច្ចេកទេសឱ្យបានគ្រប់ជ្រុងជ្រោយ
- ក្នុងការចុះពិនិត្យវាយតម្លៃ បុគ្គលិកទទួលបន្ទុកវិស័យប្រេងកាតត្រូវរៀបចំកំណត់ហេតុស្តីពីការចុះពិនិត្យទីតាំងសន្និធិ (គំរូកំណត់ហេតុត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃវិស័យប្រេងកាត) ដោយផ្តល់យោបល់ច្បាស់លាស់លើទិដ្ឋភាពបរិស្ថាន សង្គម សេដ្ឋកិច្ច និងបទប្បញ្ញត្តិបច្ចេកទេសលើសេវាដែលបានស្នើសុំនោះ
- បុគ្គលិកទទួលបន្ទុកវិស័យប្រេងកាតត្រូវរៀបចំ "កំណត់បង្ហាញរឿង" ដោយមានភ្ជាប់មកជាមួយនូវកំណត់ហេតុស្តីពីការចុះពិនិត្យទីតាំងសន្និធិដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ ព្រមទាំងរៀបចំសេចក្តីព្រាងលិខិតអនុញ្ញាតនិងសេចក្តីសម្រេចស្តីពីលក្ខខណ្ឌនៃលិខិតអនុញ្ញាត (គំរូលិខិតអនុញ្ញាតនិងគំរូសេចក្តីសម្រេចស្តីពីលក្ខខណ្ឌនៃលិខិតអនុញ្ញាតត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃវិស័យប្រេងកាត) ឬលិខិតឆ្លើយតបក្នុងករណីបដិសេធដោយត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ រួចបញ្ជូនទៅប្រធានការិយាល័យច្រកចេញចូលតែមួយ
- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីបុគ្គលិកទទួលបន្ទុកវិស័យប្រេងកាតលើ "កំណត់បង្ហាញរឿង" ប្រធានការិយាល័យច្រកចេញចូលតែមួយត្រូវបញ្ជូនសំណុំឯកសារស្នើសុំ សេចក្តីព្រាងលិខិតអនុញ្ញាតនិងសេចក្តីសម្រេចស្តីពីលក្ខខណ្ឌនៃលិខិតអនុញ្ញាត ឬលិខិតឆ្លើយតបក្នុងករណីបដិសេធជូនអភិបាលក្រុង ស្រុក ខណ្ឌ ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

ក្នុងការពិនិត្យសម្រេចផ្តល់លិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មបោក់ឧស្ម័នឥន្ធនៈក្នុងកំប៉ុងនិង/ឬធុងដែលមានចំណុះ៤៥គីឡូក្រាមចុះក្រោម អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

ក- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត បទប្បញ្ញត្តិបច្ចេកទេស បទប្បញ្ញត្តិស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ខ- ផ្អែកលើលទ្ធផលវាយតម្លៃបច្ចេកទេស។

គ- មិនមានផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច សង្គម សុខភាព សុវត្ថិភាពសាធារណៈ និងបរិស្ថាន។

ឃ- មានសង្គតិភាពជាមួយនឹងផែនការអភិវឌ្ឍដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានអនុម័ត។

ង- ទីតាំងសន្និធិកំប៉ុងនិង/ឬធុងឧស្ម័នឥន្ធនៈត្រូវស្ថិតនៅដាច់ដោយឡែក។

ច- ទីតាំងដែលជាផ្ទះល្វែងមួយល្វែងហើយស្ថិតនៅជាប់ៗគ្នាជាមួយផ្ទះដទៃទៀត មិនអនុញ្ញាតឱ្យមានសន្និធិឧស្ម័នឥន្ធនៈដើម្បីធ្វើអាជីវកម្មលើសពី៥០០(ប្រាំរយ) គីឡូក្រាមឡើយ។

**ឃ. ការគ្រប់គ្រង**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបញ្ជីការផ្តល់លិខិតសន្និធិធ្វើអាជីវកម្មលក់ឧស្ម័នឥន្ធនៈក្នុងកំប៉ុងនិង/ឬធុងដែលមានចំណុះ៤៥គីឡូក្រាមចុះក្រោម ដែលមានទីតាំងនៅក្នុងមូលដ្ឋានរបស់ខ្លួននិងត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់យ៉ាងតិចមួយឆមាសម្តង។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ចែងឱ្យមានការចុះត្រួតពិនិត្យជាប្រចាំយ៉ាងតិច៦(ប្រាំមួយ) ខែម្តងលើទីតាំងជាក់ស្តែងដែលបានផ្តល់លិខិតអនុញ្ញាត ដើម្បីធានាអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសនានាដែលបានអនុញ្ញាត និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងទិដ្ឋភាពបរិស្ថាន សង្គម សេដ្ឋកិច្ច។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចម្លងជូនមកមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់ នូវលិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់ឧស្ម័នឥន្ធនៈក្នុងកំប៉ុងនិង/ឬធុងដែលមានចំណុះ៤៥ គីឡូក្រាមចុះក្រោម រៀងរាល់ដើមត្រីមាសនីមួយៗ។

## ២. ការគ្រប់គ្រងនិងការអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់និងប្តូរប្រេងរំអិល

**ក. គោលការណ៍នៃការផ្តល់សេវា**

លិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់និងប្តូរប្រេងរំអិល អាចផ្តល់បានដោយប្រើប្រាស់ប្រភេទផ្ទុកនិងកម្រិតសន្និធិជាក់ស្តែងសរុបដូចខាងក្រោម៖

-ប្រើកំប៉ុងឬធុង ដែលមានចំណុះប្រេងរំអិល២០០(ពីររយ) លីត្រចុះក្រោម និង

-មានសន្និធិ(ស្តុក)ជាក់ស្តែងសរុបចាប់ពី២០១(ពីររយមួយ) លីត្រ ដល់១៥០ ០០០ (មួយរយហាសិបពាន់) លីត្រ។

ការអនុញ្ញាតឱ្យធ្វើអាជីវកម្មដូចចំណុចខាងលើត្រូវផ្អែកតាមបទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពជាធរមាន។

**ខ. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់**

បុគ្គលគ្រប់រូបដែលមានបំណងស្នើសុំលិខិតអនុញ្ញាតសន្និធិសម្រាប់អាជីវកម្មលក់និងប្តូរប្រេងរំអិល ឬមានបំណងស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសន្និធិ ត្រូវមកទទួលពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រូវបំពេញពាក្យស្នើសុំដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃវិស័យប្រេងកាតដូចខាងក្រោម៖

១- ពាក្យស្នើសុំលិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់និងប្តូរប្រេងរំអិល...... ចំនួន១ច្បាប់

២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងដោយមានការបញ្ជាក់ពីអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច.................................................................... ចំនួន១ច្បាប់

៣- លក្ខន្តិកៈក្រុមហ៊ុននិងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានការ បញ្ជាក់ពីអាជ្ញាធរឬស្ថាប័នមានសមត្ថកិច្ច(ក្នុងករណីជានីតិបុគ្គល).................. ចំនួន១ច្បាប់

៤- លិខិតប្រគល់សិទ្ធិជាតំណាង(ក្នុងករណីអ្នកស្នើសុំជាតំណាងឱ្យនីតិបុគ្គល)... ចំនួន១ច្បាប់

៥- រូបថតម្ចាស់អាជីវកម្ម ឬប្រធានក្រុមហ៊ុន ៤x៦............................................ ចំនួន៣សន្លឹក

### គ. នីតិវិធីនៃការផ្តល់សេវា

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវនិងគ្រប់គ្រាន់ ប្រជាពលរដ្ឋត្រូវមកដាក់ពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងស្នើសុំនោះស្ថិតនៅ។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំពីប្រធានការិយាល័យច្រកចេញចូលតែមួយ បុគ្គលិកទទួលបន្ទុកវិស័យប្រេងកាតត្រូវពិនិត្យនិងវាយតម្លៃលើពាក្យស្នើសុំនិងត្រូវចុះពិនិត្យវាយតម្លៃទីតាំងស្នើសុំលើទិដ្ឋភាពបរិស្ថាន សង្គម សេដ្ឋកិច្ច និងបទប្បញ្ញត្តិបច្ចេកទេសឱ្យបានគ្រប់ជ្រុងជ្រោយ
- ក្នុងការចុះពិនិត្យវាយតម្លៃ បុគ្គលិកទទួលបន្ទុកវិស័យប្រេងកាតត្រូវរៀបចំកំណត់ហេតុស្តីពីការចុះពិនិត្យទីតាំងសន្និធិ (គំរូកំណត់ហេតុត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃវិស័យប្រេងកាត) ដោយផ្តល់យោបល់ច្បាស់លាស់លើទិដ្ឋភាពបរិស្ថាន សង្គម សេដ្ឋកិច្ច និងបទប្បញ្ញត្តិបច្ចេកទេសលើសេវាដែលបានស្នើសុំនោះ
- បុគ្គលិកទទួលបន្ទុកវិស័យប្រេងកាតត្រូវរៀបចំ "កំណត់បង្ហាញរឿង" ដោយមានភ្ជាប់មកជាមួយនូវកំណត់ហេតុស្តីពីការចុះពិនិត្យទីតាំងសន្និធិដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ ព្រមទាំងរៀបចំសេចក្តីព្រាងលិខិតអនុញ្ញាតនិងសេចក្តីសម្រេចស្តីពីលក្ខខណ្ឌនៃលិខិតអនុញ្ញាត (គំរូលិខិតអនុញ្ញាតនិងគំរូសេចក្តីសម្រេចស្តីពីលក្ខខណ្ឌនៃលិខិតអនុញ្ញាតត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃវិស័យប្រេងកាត) ឬលិខិតឆ្លើយតបក្នុងករណីបដិសេធដោយត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ រួចបញ្ជូនទៅប្រធានការិយាល័យច្រកចេញចូលតែមួយ
- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីបុគ្គលិកទទួលបន្ទុកវិស័យប្រេងកាតលើ "កំណត់បង្ហាញរឿង" ប្រធានការិយាល័យច្រកចេញចូលតែមួយត្រូវបញ្ជូនសំណុំឯកសារស្នើសុំ សេចក្តីព្រាងលិខិតអនុញ្ញាតនិងសេចក្តីសម្រេចស្តីពីលក្ខខណ្ឌនៃលិខិតអនុញ្ញាត ឬលិខិតឆ្លើយតបក្នុងករណីបដិសេធជូនអភិបាលក្រុង ស្រុក ខណ្ឌ ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

ក្នុងការពិនិត្យសម្រេចផ្តល់លិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់និងប្តូរប្រេងរំអិល អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

ក- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត បទប្បញ្ញត្តិបច្ចេកទេស បទប្បញ្ញត្តិស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ខ- ផ្អែកលើលទ្ធផលវាយតម្លៃបច្ចេកទេស។

គ- មិនមានផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច សង្គម សុខភាព សុវត្ថិភាពសាធារណៈ និងបរិស្ថាន។

ឃ- មានសង្គតិភាពជាមួយនឹងផែនការអភិវឌ្ឍដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានអនុម័ត។

ង- កំពស់ឬធុងប្រេងរំអិលត្រូវមានចំណុះស្មើ២០០(ពីររយ) លីត្រចុះក្រោម។

### ឃ. ការគ្រប់គ្រង

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបញ្ជីការផ្តល់លិខិតសន្និធិធ្វើអាជីវកម្មលក់និងប្តូរប្រេងរំអិល ដែលមានទីតាំងនៅក្នុងមូលដ្ឋានរបស់ខ្លួននិងត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់យ៉ាងតិចមួយឆមាសម្តង។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ចែងឱ្យមានការចុះត្រួតពិនិត្យជាប្រចាំយ៉ាងតិច៦(ប្រាំមួយ) ខែម្តងលើទីតាំងជាក់ស្តែងដែលបានផ្តល់លិខិតអនុញ្ញាត ដើម្បីធានាអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេស នានាដែលបានអនុញ្ញាត និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងចីរភាពបរិស្ថាន សង្គម សេដ្ឋកិច្ច។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចម្លងជូនមកមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់ នូវលិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់និងប្តូរប្រេងរំអិល រៀងរាល់ដើមត្រីមាសនីមួយៗ។

## III- កម្រៃសេវា រយៈពេល និងសុពលភាពនៃការផ្តល់សេវា

កម្រៃសេវានិងរយៈពេលនៃការផ្តល់សេវាសម្រាប់អាជ្ញាបណ្ណ លិខិតបញ្ជាក់នៃការចុះបញ្ជី និងលិខិតអនុញ្ញាតសម្រាប់ការស្នើសុំសេវាខាងលើត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត និងលិខិតបញ្ជាក់នៃការចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មស័ណ្ឋាន មានសុពលភាព ១ (មួយ)ឆ្នាំ និងមិនអាចស្នើសុំបន្តសុពលភាពបាន។ ចំពោះលិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់ឧស្ម័នឥន្ធនៈក្នុងកំប៉ុងនិង/ឬធុងដែលមានចំណុះ៤៥ គីឡូក្រាមចុះក្រោមនិងលិខិតអនុញ្ញាតសន្និធិដើម្បីធ្វើអាជីវកម្មលក់និងប្តូរប្រេងរំអិល មានសុពលភាព ២ (ពីរ)ឆ្នាំ និងអាចស្នើសុំបន្តសុពលភាពបាន។

## IV- សោហ៊ុយសារនិងឈ្នួលដី

សោហ៊ុយសារនិងឈ្នួលដីនៃអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត ត្រូវអនុវត្តស្របតាមប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## V- របាយការណ៍

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសអំពីការអនុវត្តមុខងារក្នុងវិស័យរ៉ែនិងប្រេងកាតមករដ្ឋបាលរាជធានី ខេត្ត ដោយចម្លងជូនក្រសួងមហាផ្ទៃ និងមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់ រៀងរាល់ដើមត្រីមាសនីមួយៗ។ របាយការណ៍ប្រចាំត្រីមាសត្រូវរៀបចំស្របតាមការកំណត់ដូចមានភ្ជាប់ក្នុងទម្រង់របាយការណ៍ឧបសម្ព័ន្ធរួមនៃវិស័យរ៉ែនិងប្រេងកាត។

មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវធ្វើការបូកសរុបនិងរាយការណ៍ជូនក្រសួងរ៉ែនិងថាមពលអំពីការអនុវត្តមុខងារក្នុងវិស័យរ៉ែនិងប្រេងកាតរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងអំឡុងពេល១៥ថ្ងៃនៃត្រីមាសបន្ទាប់។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងរ៉ែនិងថាមពល និងគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពនិងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ៣រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែសីហា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**<u>កន្លែងទទួល</u>៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត
- គ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃវិស័យរ៉ែ ភ្ជាប់និងសេចក្តីណែនាំលេខ ០៥០... ចុះថ្ងៃទី ៧ ខែ សីហា
ឆ្នាំ២០២០ ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យរ៉ែ
និងប្រេងកាតរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

*(ឧបសម្ព័ន្ធទី១នៃវិស័យរ៉ែ គំរូពាក្យស្នើសុំ)*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត ៤x៦

# ពាក្យស្នើសុំ
## អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ
## សម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................ភេទ......... អាយុ........ឆ្នាំ សញ្ជាតិ...............
កាន់អត្តសញ្ញាណបណ្ណលេខ.....................................ចុះថ្ងៃទី..........ខែ..............ឆ្នាំ...................
អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ....................ផ្លូវលេខ..........ភូមិ.....................ឃុំ/សង្កាត់.......................
ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត.........................សៀវភៅស្នាក់នៅលេខ.................
ចុះថ្ងៃទី.........ខែ..........ឆ្នាំ..........ទូរស័ព្ទទំនាក់ទំនងលេខ................................ ។

**សូមគោរពជូន**

**លោក/លោកស្រី អភិបាលនៃគណៈអភិបាលក្រុង / ស្រុក / ខណ្ឌ.........................**

**កម្មវត្ថុ** ៖ សំណើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត។

**យោង** ៖ សេចក្តីណែនាំលេខ............ចុះថ្ងៃទី........ខែ...........ឆ្នាំ........ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យរ៉ែនិងប្រេងកាតរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **លោក/លោកស្រីអភិបាល** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងស្នើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត នៅក្រុង/ស្រុក/ខណ្ឌ.................................រាជធានី/ខេត្ត..........................
ដែលមានគម្រោងផែនការអាជីវកម្មដូចខាងក្រោម៖

១.បរិក្ខារ

| ល.រ | ប្រភេទគ្រឿងចក្រ (កាយ ចូក ដឹក) | ម៉ាកគ្រឿងចក្រ | កម្លាំងម៉ាស៊ីន | ទំហំប៉ែល / ចំណុះផ្ទុក |
|---|---|---|---|---|
| ១ | .............................. | .............................. | .............................. | .............................. |
| ២ | .............................. | .............................. | .............................. | .............................. |
| ៣ | .............................. | .............................. | .............................. | .............................. |
| ៤ | .............................. | .............................. | .............................. | .............................. |
| ៥ | .............................. | .............................. | .............................. | .............................. |
| ...... | .............................. | .............................. | .............................. | .............................. |

ចំនួនរថយន្តដឹក៖..............................

ចំនួនកម្លាំងពលកម្ម ........................នាក់ ស្រី........................នាក់

ទុនវិនិយោគ ........................................................ (ទុនផ្ទាល់ខ្លួន □ កម្ចីធនាគារ □)

ខ្ញុំបាទ/នាងខ្ញុំ សូមអះអាងថាព័ត៌មានទាំងរស់ខាងលើពិតជាត្រឹមត្រូវ។ បើមិនដូច្នោះ ខ្ញុំបាទ/នាងខ្ញុំ/នឹងទទួលខុសត្រូវចំពោះមុខច្បាប់។

អាស្រ័យដូចបានគោរពជម្រាបជូនក្នុងកម្មវត្ថុខាងលើ សូម**លោក/លោកស្រីអភិបាល** មេត្តាអនុញ្ញាតផ្តល់អាជ្ញាបណ្ណសិប្បកម្មចនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត ដោយក្តីអនុគ្រោះ។

សូម **លោក/លោកស្រីអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

<u>សូមជូនឯកសារភ្ជាប់មកជាមួយនូវ៖</u>

១- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរថតចម្លងដោយមានការបញ្ជាក់ពីអាជ្ញាធរឬស្ថាប័នមានសមត្ថកិច្ច.................................................... ចំនួន១ច្បាប់

២- សៀវភៅស្នាក់នៅថតចម្លងដោយមានការបញ្ជាក់ពីអាជ្ញាធរឬស្ថាប័នមានសមត្ថកិច្ច.................................................... ចំនួន១ច្បាប់

៣- រូបថត ៤x៦.................................................... ចំនួន៣សន្លឹក

ថ្ងៃ.......................ខែ...............ឆ្នាំ................ ព.ស. ........

ធ្វើនៅ............... ថ្ងៃទី....... ខែ........ ឆ្នាំ.........

ហត្ថលេខា ឬស្នាមមេដៃអ្នកស្នើសុំ

(ឧបសម្ព័ន្ធទី២នៃវិស័យរ៉ែ គំរូអាជ្ញាបណ្ណ)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

(Logoក្រុង/ស្រុក/ខណ្ឌ)

**រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ......................**

លេខ:....................................

# អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ
# សម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត

អនុញ្ញាតឱ្យលោក/លោកស្រី..............................ភេទ..........អាយុ..........អាសយដ្ឋានផ្ទះលេខ..........ផ្លូវលេខ..............ភូមិ..............
ឃុំ/សង្កាត់..............................ក្រុង/ស្រុក/ខណ្ឌ..............................រាជធានី/ខេត្ត..............................ធ្វើប្រតិបត្តិការសេវាកម្មជីកអាចម៍ដី
រណ្តៅដីចល័ត នៅក្រុង/ស្រុក/ខណ្ឌ..............................រាជធានី/ខេត្ត..............................។
លោក/លោកស្រី..............................ត្រូវដំណើរការប្រតិបត្តិការធនធានរ៉ែក្នុងស្រុក ខាងលើស្របតាមសេចក្តីសម្រេចលេខ..............
ចុះថ្ងៃទី..............ខែ..............ឆ្នាំ២០........ស្តីពីលក្ខខណ្ឌនៃអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត។
អាជ្ញាបណ្ណនេះមានសុពលភាព១ ឆ្នាំ ចាប់ពីថ្ងៃទី..........ខែ..........ឆ្នាំ.......... ដល់ថ្ងៃទី..........ខែ..........ឆ្នាំ..........។

ថ្ងៃ....................ខែ..............ឆ្នាំ..............ព.ស..............

....................ថ្ងៃទី..............ខែ..............ឆ្នាំ..............

**អភិបាល**

ONE WINDOW SERVICE OFFICE

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(Logo ក្រុង/ស្រុក/ខណ្ឌ)

**រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ...............**

លេខ៖............................

# សេចក្តីសម្រេច
# ស្តីពី
# លក្ខខណ្ឌអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ សម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត

**អភិបាលនៃគណៈអភិបាលក្រុង/ស្រុក/ខណ្ឌ..................**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល

- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញសារាចរលេខ០៣១០ រថ.អធរ.សរច. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ ស្តីពីវិធានការចំពោះការដឹកជញ្ជូនរ៉ែសំណង់គ្រប់ប្រភេទ
- បានឃើញសេចក្តីណែនាំលេខ..............ចុះថ្ងៃទី..........ខែ.........ឆ្នាំ...........ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យរ៉ែនិងប្រេងកាតរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

## សម្រេច

### ប្រការ១ .. គោលបំណង

សេចក្តីសម្រេចនេះ មានគោលបំណងកំណត់លក្ខខណ្ឌភ្ជាប់នឹងអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត លេខ............. ចុះថ្ងៃទី........ ខែ........ ឆ្នាំ២០....អនុញ្ញាតឱ្យលោក/លោកស្រី..................................មានអាសយដ្ឋានផ្ទះលេខ.......................ផ្លូវលេខ.................ភូមិ.................................ឃុំ/សង្កាត់......................................ក្រុង/ស្រុក/ខណ្ឌ..............................រាជធានី/ខេត្ត...................................(អ្នកទទួលបានអាជ្ញាបណ្ណ) ធ្វើប្រតិបត្តិការសេវាកម្មជីកអាចម៍ដី រណ្តៅដីចល័តនៅក្នុងក្រុង/ស្រុក/ខណ្ឌ.........................................រាជធានី/ខេត្ត.............................................។

អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី រណ្តៅដីចល័ត មានសុពលភាព ១ (មួយ) ឆ្នាំ និងមិនអាចពន្យារបន្តបានទេ។ អ្នកទទួលបានអាជ្ញាបណ្ណត្រូវបំពេញបែបបទស្នើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែថ្មីឡើងវិញ ក្នុងករណីមានបំណងធ្វើប្រតិបត្តិការធនធានរ៉ែក្រោយផុតរយៈពេលសុពលភាពនៃអាជ្ញា-បណ្ណសិប្បកម្មធនធានរ៉ែនោះ។

### ប្រការ២ .. កាតព្វកិច្ចអនុលោមតាមបទប្បញ្ញត្តិច្បាប់

អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវធ្វើប្រតិបត្តិការធនធានរ៉ែស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ សេចក្តីសម្រេចនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ៣ .. លក្ខខណ្ឌបច្ចេកទេស

អ្នកទទួលបានអាជ្ញាបណ្ណត្រូវធ្វើប្រតិបត្តិការធនធានរ៉ែ នៅក្នុងភូមិ/ឃុំនៃស្រុកដែលបានស្នើសុំនិងប្រើប្រាស់តែយានយន្ត/គ្រឿងចក្រដែលបានអនុញ្ញាតដូចក្នុងតារាងខាងក្រោម៖

| ល.រ | ប្រភេទគ្រឿងចក្រ (កាយ ចូក ដឹក) | ម៉ាកគ្រឿងចក្រ | កម្លាំងម៉ាស៊ីន | ទំហំប៉ែល / ចំណុះផ្ទុក |
|---|---|---|---|---|
| ១ | ............ | ............ | ............ | ............ |
| ២ | ............ | ............ | ............ | ............ |
| ៣ | ............ | ............ | ............ | ............ |
| ៤ | ............ | ............ | ............ | ............ |
| ៥ | ............ | ............ | ............ | ............ |
| ...... | ............ | ............ | ............ | ............ |

## ប្រការ៤ _ ភារកិច្ចពាក់ព័ន្ធនឹងប្រតិបត្តិការ

អ្នកទទួលបានអាជ្ញាបណ្ណត្រូវប្រកាន់ខ្ជាប់នូវលក្ខខណ្ឌដូចខាងក្រោម៖

- មុននឹងចាប់ផ្តើមធ្វើប្រតិបត្តិការដឹកយករ៉ែភាចម៍ដីនៅទីតាំងជាក់ស្តែងណាមួយ អ្នកទទួលបានអាជ្ញាបណ្ណត្រូវស្នើសុំលិខិតអង្កេតសុរិជាន អតុរិជានពីរដ្ឋបាលឃុំ សង្កាត់ ដែលទីតាំងដឹកយករ៉ែភាចម៍ដីនោះស្ថិតនៅ និងត្រូវជូនដំណឹងមករដ្ឋបាលក្រុង ស្រុក ខណ្ឌ មុន ៣ (បី)ថ្ងៃ យ៉ាងតិចអំពីទីតាំងជាក់ស្តែងដែលត្រូវដឹកយករ៉ែភាចម៍ដី ទីតាំងដែលត្រូវចាក់បំពេញ ថ្ងៃខែចាប់ផ្តើម និងក្នុងរយៈពេល១ (មួយ)ថ្ងៃ យ៉ាងយូរក្រោយពីបញ្ចប់ការដឹកយករ៉ែភាចម៍ដីនៅទីតាំងស្នើសុំនោះ
- ប្រកាន់យកគោលការណ៍សុវត្ថិភាពជាចម្បង និងប្រើប្រាស់រាល់វិធានការចាំបាច់ដើម្បីរក្សាសុវត្ថិភាព និងសុខភាពរបស់កម្មករក្នុងដំណើរការប្រតិបត្តិការធនធានរ៉ែ
- ការពារមិនឱ្យមានគ្រោះថ្នាក់ជាយថាហេតុក្នុងប្រតិបត្តិការធនធានរ៉ែ
- ការពារមិនឱ្យមានការរំខានដោយសម្លេង ការបំពុលធូលី ឬរញ្ជួយ ឬកំពប់ដី ដោយមានវិធានការបាញ់ទឹកគ្រប ឬប្រើវិធីផ្សេងៗតាមការចាំបាច់ស្របតាមសារាចរលេខ០៣១០ រ៉ច.អធរ.សរច. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ ស្តីពីវិធានការចំពោះការដឹកជញ្ជូនរ៉ែសំណង់គ្រប់ប្រភេទ
- ការពារមិនឱ្យមានការបាក់ដី ឬខូចទ្រង់ទ្រាយដីនៅក្រៅតំបន់ប្រតិបត្តិការ
- រក្សាគម្លាតសុវត្ថិភាពយ៉ាងតិច២៥ម៉ែត្រពីមាត់រណ្តៅទៅច្រាំងនៃបឹង ទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ ស្រះ
- រក្សាគម្លាតយ៉ាងតិច១០ម៉ែត្រពីមាត់រណ្តៅដីនីមួយៗ និងមិនត្រូវដឹកជាន់លើរណ្តៅដីចាស់ដែលមានស្រាប់ និង
- រក្សាគម្លាតយ៉ាងតិច៥ម៉ែត្រពីមាត់រណ្តៅទៅព្រំដីនៅជុំវិញ។

ក្នុងករណីមានផលប៉ះពាល់ដល់សហគមន៍មូលដ្ឋាន អ្នកទទួលបានអាជ្ញាបណ្ណត្រូវទទួលខុសត្រូវតាមរយៈការជួសជុល ប៉ះប៉ូវ ឬសងការខូចខាត តាមការព្រមព្រៀងជាមួយនឹងអាជ្ញាធរមូលដ្ឋាននិងភាគីប៉ះពាល់។

## ប្រការ៥ _ ភារកិច្ចហិរញ្ញវត្ថុ

អ្នកទទួលបានអាជ្ញាបណ្ណត្រូវបង់កម្រៃសេវាសាធារណៈ សួយសារ ឈ្នួលដី ស្របតាមប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងរ៉ែនិងថាមពល និងត្រូវបង់ពន្ធ អាករ និងភារកិច្ចហិរញ្ញវត្ថុផ្សេងទៀតស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ៦ .. ភារកិច្ចកត់ត្រា ផ្តល់របាយការណ៍ និងសម្របសម្រួលដល់អធិការកិច្ច**

អ្នកទទួលបានអាជ្ញាបណ្ណត្រូវ៖

- កត់ត្រា និងរក្សាទុកកំណត់ត្រាប្រតិបត្តិការជីកអាចម៍ដី ប្រចាំថ្ងៃរបស់ខ្លួន ដោយមានបញ្ជាក់ទីតាំងជីកយកនិងបរិមាណអាចម៍ដីដែលទាញយក
- ផ្ញើរបាយការណ៍បូកសរុបប្រតិបត្តិការប្រចាំខែជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង
- សម្រួលដល់ការត្រួតពិនិត្យនិងធ្វើអធិការកិច្ចរបស់មន្ត្រីមានសមត្ថកិច្ច។

**ប្រការ៧ .. ការល្មើស**

អ្នកទទួលបានអាជ្ញាបណ្ណដែលប្រព្រឹត្តល្មើសបញ្ញត្តិណាមួយនៃសេចក្តីសម្រេចនេះនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានទោះដោយចេតនាក្តីឬអចេតនាក្តី នឹងត្រូវទទួលការផាកពិន័យ ឬការព្យួរ ឬការដកហូតអាជ្ញាបណ្ណ។

**ប្រការ៨ .. សុពលភាព**

សេចក្តីសម្រេចនេះមានសុពលភាពស្របទៅតាមសុពលភាពនៃអាជ្ញាបណ្ណ ដូចមានចែងក្នុងប្រការ១។

**ប្រការ៩ .. ការអនុវត្ត**

នាយករដ្ឋបាល ប្រធានការិយាល័យច្រកចេញចូលតែមួយ ប្រធានការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍសហគមន៍ និងលោក/លោកស្រី...................... ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន។

ថ្ងៃ..................ខែ................ ឆ្នាំ.............. ព.ស ..........

................. ថ្ងៃទី....... ខែ.......... ឆ្នាំ..........

**អភិបាល**

<u>ចម្លងជូន៖</u>

- រដ្ឋបាលរាជធានី ខេត្ត.............
- មន្ទីររ៉ែនិងថាមពល រាជធានី ខេត្ត..................
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត..........
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាជធានី ខេត្ត...........
- មន្ទីរបរិស្ថានរាជធានី ខេត្ត...................
- មន្ទីរកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រាជធានី ខេត្ត...................
- ដូចប្រការ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

*(ឧបសម្ព័ន្ធទី៣នៃវិស័យរ៉ែ គំរូលិខិតអង្កេតសុវិធាន អសុវិធាន)*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលឃុំ/សង្កាត់**.................................

លេខ:...............................................

# លិខិតអង្កេតសុវិធាន អសុវិធាន

យើងខ្ញុំ មេឃុំ/សង្កាត់..................................................... សូមបញ្ជាក់ថា ទីតាំងស្នើសុំជីកយកអាចម៍ដីរបស់លោក/លោកស្រី.................................................ដែលស្ថិតនៅ.................................... ភូមិ...................................ឃុំ/សង្កាត់.................................ក្រុង/ស្រុក/ខណ្ឌ.................................... រាជធានី/ខេត្ត......................................មានស្ថានភាពភូមិសាស្ត្រដូចខាងក្រោម៖

- ..........................................................................................................................
- ..........................................................................................................................
- ..........................................................................................................................
- ..........................................................................................................................
- ..........................................................................................................................

សន្និដ្ឋាន៖

..........................................................................................................................
..........................................................................................................................។

ថ្ងៃ............................. ខែ............. ឆ្នាំ........................... ព.ស.........

......................... ថ្ងៃទី.................ខែ.......................ឆ្នាំ.................

**មេឃុំ / ចៅសង្កាត់**....................

(ហត្ថលេខានិងត្រា)

*(ឧបសម្ព័ន្ធទី៥នៃវិស័យរ៉ែ គំរូបញ្ជីអាជ្ញាបណ្ណ)*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Logo (ក្រុង/ស្រុក/ខណ្ឌ)

**រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ**................

## បញ្ជីអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ

យោងសេចក្តីណែនាំស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យរ៉ែនិងប្រេងកាតរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

| ល.រ | អ្នកទទួលបានអាជ្ញាបណ្ណ | | អាជ្ញាបណ្ណ (លេខ/ថ្ងៃខែឆ្នាំ) | សេចក្តីសម្រេចស្តីពីការផ្តល់អាជ្ញាបណ្ណ (លេខ/ថ្ងៃខែឆ្នាំ) | សុពលភាព | |
|---|---|---|---|---|---|---|
| | ឈ្មោះ | លេខអត្តសញ្ញាណប័ណ្ណ | | | ចាប់ពី | ដល់ |
| | | | | | | |
| | | | | | | |
| | | | | | | |

ថ្ងៃ..................ខែ....................ឆ្នាំ..............ព.ស ..........

..................ថ្ងៃទី.........ខែ..........ឆ្នាំ..........

អ្នករៀបចំបញ្ជី

(ឧបសម្ព័ន្ធទី៥នៃវិស័យរ៉ែ គំរូពាក្យស្នើសុំ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត ៤x៦

## ពាក្យស្នើសុំចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្ម ផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................ភេទ.........អាយុ........ឆ្នាំ សញ្ជាតិ.................
កាន់អត្តសញ្ញាណប័ណ្ណលេខ.................................ចុះថ្ងៃទី.........ខែ.............ឆ្នាំ...............
អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ផ្លូវលេខ..........ភូមិ...................ឃុំ/សង្កាត់.................
ក្រុង/ស្រុក/ខណ្ឌ..........................រាជធានី/ខេត្ត.......................សៀវភៅស្នាក់នៅលេខ..........
ចុះថ្ងៃទី........ខែ..........ឆ្នាំ..........ទូរស័ព្ទទំនាក់ទំនងលេខ.............................។

បំពេញព័ត៌មានខាងក្រោម ក្នុងករណីជានីតិបុគ្គលៈ

នាមករណ៍ក្រុមហ៊ុន/សហគ្រាស.................................លេខចុះបញ្ជីពាណិជ្ជកម្ម.....................
អាសយដ្ឋានក្រុមហ៊ុន/សហគ្រាស..........................................................................
......................................................................................................
ទូរស័ព្ទទំនាក់ទំនងលេខ.................................អ៊ីម៉ែល.......................................។

**សូមគោរពជូន**
**លោក/លោកស្រី អភិបាលនៃគណៈអភិបាលក្រុង / ស្រុក / ខណ្ឌ.......................**

**កម្មវត្ថុ** ៖ សំណើសុំចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់។
**យោង** ៖ សេចក្តីណែនាំលេខ.........ចុះថ្ងៃទី.........ខែ.........ឆ្នាំ.........ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យរ៉ែនិងប្រេងកាតរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **លោក/លោកស្រី អភិបាល** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងស្នើសុំចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់ នៅភូមិ......................ឃុំ/សង្កាត់.......................ក្រុង/ស្រុក/ខណ្ឌ......................
រាជធានី/ខេត្ត.................................. ដែលមាន**គម្រោងផែនការអាជីវកម្ម**ដូចខាងក្រោមៈ

១. គោលបំណងអាជីវកម្ម

□ ធ្វើពាណិជ្ជកម្មទូទៅ

□ ផ្គត់ផ្គង់ឱ្យគម្រោងៈ រាជធានី/ខេត្ត □ ក្រុង/ស្រុក/ខណ្ឌ □ ឃុំ/សង្កាត់ □

( ប្រភេទគម្រោង...............................................................

២.អំពីទីតាំងដេប៉ូ

ទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ ក្រួស និងថ្មសំណង់ស្ថិតនៅភូមិ...........................................

ឃុំ/សង្កាត់.............................ក្រុង/ស្រុក/ខណ្ឌ...........................រាជធានី/ខេត្ត...........................។

ក្រឡាផ្ទៃទីតាំងដេប៉ូ (ម២)...........................................................................................

ព្រំប្រទល់ខាងកើតជាប់នឹង...........................................................................................

ព្រំប្រទល់ខាងជើងជាប់នឹង...........................................................................................

ព្រំប្រទល់ខាងត្បូងជាប់នឹង...........................................................................................

ព្រំប្រទល់ខាងលិចជាប់នឹង...........................................................................................

**គំនូសប្លង់ទីតាំងស្នើសុំ**

៣. មធ្យោបាយ

| ល.រ | ប្រភេទគ្រឿងចក្រ (កាយ ចូក ដឹក) | ម៉ាក គ្រឿងចក្រ | កម្លាំងម៉ាស៊ីន | ទំហំប៉ែល / ចំណុះផ្ទុក |
|---|---|---|---|---|
| ១ | ............................ | ............................ | ............................ | ............................ |
| ២ | ............................ | ............................ | ............................ | ............................ |
| ៣ | ............................ | ............................ | ............................ | ............................ |
| ៤ | ............................ | ............................ | ............................ | ............................ |
| ៥ | ............................ | ............................ | ............................ | ............................ |
| ...... | ............................ | ............................ | ............................ | ............................ |

ចំនួនរថយន្តដឹក៖..............................

ចំនួនកម្លាំងពលកម្ម..............................នាក់ ស្រី.................... នាក់

